# ទិដ្ឋាការចេញចូលច្រើនដងសម្រាប់ជនជាតិខ្មែររស់នៅកម្ពុជា

សូមរៀបឯកសារដូចខាងក្រោម សម្រាប់ជនជាតិខ្មែរដែលមានបំណងទៅជប៉ុនច្រើនដង "ក្នុងរយៈពេលខ្លី" គោលបំណងទេសចរណ៍ ទៅលេងសាច់ញាតិ ឬអ្នកមិត្តភក្តិ ។ល។

ទិដ្ឋាការនេះមានសុពលភាពអតិបរមា៣ឆ្នាំ (ករណីខ្លះទទួលបាន១ឆ្នាំ) និងអាចស្នាក់នៅម្តងរយៈពេល១៥ថ្ងៃ។(ជនជាតិខ្មែរដែលរស់នៅក្រៅប្រទេសមិនអាចដាក់បានទេ)

ទិដ្ឋាការចេញចូលច្រើនដងសម្រាប់គោលបំណង ពាណិជ្ជកម្ម ឬសកម្មភាពទាក់ទងនឹងវប្បធម៌ជាដើម មានសុពលភាពអតិបរមា៣ឆ្នាំ និងអាចស្នាក់នៅម្តងរយៈពេល៩០ថ្ងៃ។

★★★ **អ្នកដែលអាចដាក់ពាក្យបាន** ★★★

១. អ្នកធ្លាប់ទៅប្រទេសជប៉ុនច្រើនដង ស្នាក់នៅរយៈពេលខ្លីក្នុងអំឡុងពេល៣ឆ្នាំចុងក្រោយដោយមិនមានកំណត់ត្រានៃការរំលោភច្បាប់ ឬបទបញ្ហាផ្សេងៗខណៈពេលស្នាក់នៅប្រទេសជប៉ុន ឬមិនមានបញ្ហាស្ថានភាពអន្តោប្រវេសន៍ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរ៉ាប់រងថ្លៃចំណាយ ឬ

២. អ្នកជំនាញដែលមានស្ថេរភាពហិរញ្ញវត្ថុ ឬ

៣. ប្តីប្រពន្ធ ឬកូនរបស់សាមីជនក្នុងលក្ខខណ្ឌ (២) ខាងលើ

| | | ឯកសារតម្រូវ | កំណត់ចំណាំ |
|---|---|---|---|
| ១ | ☐ | លិខិតឆ្លងដែន ច្បាប់ដើម | · មិនមានស្នាមប្រឡាក់ ឬការខូចខាត<br>· ត្រូវមាន២ទំព័រសម្រាប់បិទទិដ្ឋាការ |
| ២ | ☐ | ពាក្យស្នើសុំទិដ្ឋាការ *ច្បាប់ដើម*<br>*(បិទរូបថត១សន្លឹក)*<br><br>សេចក្តីពន្យល់អំពីការបំពេញពាក្យស្នើសុំ (ខ្មែរ) | · រូបថតបិទកាត (ថតថ្មីក្នុងរយៈពេល៦ខែ)<br>(បណ្តោយ: ៤.៥សង់ទីម៉ែត្រ x ទទឹង: ៣.៥សង់ទីម៉ែត្រ, ផ្ទៃពណ៌ស, រូបថតពណ៌ ឬសខ្មៅ)<br>· បំពេញពាក្យ "N/A" សម្រាប់សំណួរដែលមិនត្រូវនឹងលក្ខខណ្ឌរបស់អ្នក |
| ៣ | ☐ | ឯកសារបញ្ជាក់ពីចំណូល | · សេចក្តីចម្លងតុល្យបញ្ជីគណនី Bank statements (ធ្វើបច្ចុប្បន្នភាពកំឡុងពេល៣ខែចុងក្រោយមកទល់នឹងថ្ងៃដាក់ពាក្យស្នើទិដ្ឋាការ)<br>· ប៉ាតង់ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ (PATENT TAX) (សម្រាប់អ្នកធ្វើការអោយខ្លួនឯង) |
| ៤ | ☐ | លិខិតបញ្ជាក់ការងារ | · បញ្ជាក់៖ មុខតំណែង រយៈពេលនៃការងារ ប្រាក់បៀវត្សរ៍ ។ល។ (មិនមានកំណត់ទម្រង់) |
| ៥ | ☐ | ឯកសារបញ្ជាក់ទីលំនៅបច្ចុប្បន្ន | · ឯកសារបញ្ជាក់អាស័យដ្ឋានស្នាក់នៅកម្ពុជា |

| | | | |
|---|---|---|---|
| ៦ | □ | លិខិតស្នើសុំទិដ្ឋាការចេញចូលច្រើនដង | · សរសេរពីមូលហេតុនៃការស្នើសុំទិដ្ឋាការចេញចូលច្រើនដង។ (មិនមានកំណត់ទម្រង់) |
| ៧ | □ | ឯកសារបញ្ជាក់ពីប្រវត្តិធ្វើដំណើរចេញចូលជប៉ុន | · (ករណីប្តូរលិខិតឆ្លងដែនថ្មី)សូមភ្ជាប់មកជាមួយនូវលិខិតឆ្លងដែនចាស់ |
| ៨ | □ | ឯកសារបញ្ជាក់ពីទំនាក់ទំនង | · ករណីអ្នកអាចដាក់ពាក្យបានក្នុងលក្ខខណ្ឌទី៣ខាងលើះ ដាក់សៀវភៅគ្រួសារ សំបុត្រកំណើត។ល។ |